**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៥៦-០២២-០០៤ ប្រកាសព័ត៌មាន

ថ្ងៃ ចន្ទ ៧ កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែ មិថុនា ឆ្នាំ២០២២

# សេចក្តីប្រកាសព័ត៌មាន

## សិក្ខាសាលាស្តីពី ការផ្សព្វផ្សាយ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការសន្ទស្សន៍ថ្លៃលំនៅដ្ឋាន

នៅថ្ងៃចន្ទ ៧កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២២ នៅសណ្ឋាគារ Raffles Hotel Le Royal ធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការសន្ទស្សន៍ថ្លៃលំនៅដ្ឋាន ក្រោមអធិបតីភាព លោកជំទាវបណ្ឌិត ជា សិរី ឧបការីទេសាភិបាល និងជាអគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ដោយមានអ្នកចូលរួមអញ្ជើញមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងនាយកដ្ឋានពាក់ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា សរុបប្រមាណ ២០០នាក់ ក្នុងនោះ អ្នកចូលរួមផ្ទាល់មានប្រមាណ ៥០នាក់ និងចូលរួមតាមប្រព័ន្ធអនឡាញ (Zoom) មានប្រមាណ ១៥០នាក់។

សិក្ខាសាលានេះត្រូវបានរៀបចំដោយឈរលើទស្សនវិស័យចម្បង១ ៖ i/- តម្រូវការប្រើប្រាស់ទិន្នន័យ ៖ ការរីកលូតលាស់យ៉ាងឆាប់រហ័សនូវវិស័យអចលនទ្រព្យ និងសំណង់ ស្របពេលវិស័យនេះបានក្លាយជាសសរស្តម្ភដ៏សំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រទេសកម្ពុជា ដែលទាមទារឱ្យព័ត៌មាន និងទិន្នន័យសន្ទស្សន៍ថ្លៃលំនៅដ្ឋានត្រូវតែមានភាពរឹងមាំ គ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលា សម្រាប់ជាធាតុចូលសំខាន់ក្នុងការវិភាគ វាយតម្លៃ ចេញវិធានការណ៍ និងរៀបចំផែនការនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ii/- គុណភាព និងវិសាលភាពទិន្នន័យ ៖ ការអភិវឌ្ឍ ការពង្រឹងគុណភាព និងការពង្រីកវិសាលភាពសន្ទស្សន៍ថ្លៃលំនៅដ្ឋាន ត្រូវតែធ្វើឡើងជាប្រចាំ ដើម្បីឆ្លើយតបទៅតាមការវិវឌ្ឍលឿននូវវិស័យនេះ ដែលអាចបង្កជាហានិភ័យពាក់ព័ន្ធនានាដល់វិស័យផ្សេងទៀត ពិសេសវិស័យហិរញ្ញវត្ថុ ដែលជាប្រភពហិរញ្ញប្បទានដល់វិស័យសេដ្ឋកិច្ចក្នុងស្រុក និងកំណើនសេដ្ឋកិច្ចជារួម និង iii/- ប្រភពផ្គត់ផ្គង់ទិន្នន័យ ៖ ប្រភពផ្គត់ផ្គង់ទិន្នន័យ គឺជាបុរេលក្ខខណ្ឌចាំបាច់ដែលធានាបាននូវស្ថិរភាព ក្នុងការផលិតនិងផ្សព្វផ្សាយស្ថិតិនេះ។ ដូច្នេះ ការប្រាស្រ័យទាក់ទងគ្នានិងការយល់ពីគ្នាទៅវិញទៅមករវាង

ប្រភពផ្គត់ផ្គង់ទិន្នន័យ អ្នកចងក្រងទិន្នន័យ និងអ្នកប្រើប្រាស់ទិន្នន័យ គឺជាគន្លឹះជោគជ័យនៃការអភិវឌ្ឍសន្ទស្សន៍ថ្លៃលំនៅដ្ឋាន ប្រកបដោយចីរភាព។

សិក្ខាសាលានេះបានប្រព្រឹត្តទៅដោយជោគជ័យ និងផ្លែផ្កា ដោយមានការពិភាក្សាយ៉ាងផុលផុសលើប្រធានបទដែលវាគ្មិនកិត្តិយសបានធ្វើបទបង្ហាញ។ ការណ៍នេះសរបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់អំពីតម្លៃ និងតួនាទីដ៏សំខាន់នៃស្ថិតិក្នុងសេដ្ឋកិច្ច និងសង្គមជាតិ។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៨៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh

**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.org.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA